# ទស្សនទានវេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៣៨

# ប្រាក់អតីតភាពការងារ និងដំណោះស្រាយបណ្តឹងតវ៉ាបុគ្គលិក

*ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៩*
*ម៉ោង ៨:០០ ព្រឹក ដល់ ១៧:០០ រសៀល*
*មជ្ឈមណ្ឌលដាយកូនៀ ផ្ទះលេខ១៩-២១ ផ្លូវលេខ ៣៣០ សង្កាត់បឹងកេងកង ទី៣*

## I. សេចក្តីផ្តើម

ត្រឹមខែមិថុនា ឆ្នាំ២០១៩ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) មានសមាជិកសរុបទាំងអស់ចំនួនជាង ២០០ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុត សម្រាប់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។

**ការរៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាព** គឺជាយុទ្ធសាស្រ្តមួយ ក្នុងចំណោមយុទ្ធសាស្រ្តកម្មវិធីទាំង ៧ សម្រាប់សមាជិកភាព អង្គការ **គសក** និងអង្គការសង្គមស៊ីវិលដទៃទៀត ដែលមានមានចំណាប់អារម្មណ៍លើយុទ្ធសាស្រ្តនេះ។ ជាទូទៅ អង្គការ **គសក** រៀបចំ **វេទិការៀនសូត្រ** នេះឡើងជារៀងរាល់ឆ្នាំ មានដូចជា៖ ១. វេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្ស (HRM) ២. វេទិការៀនសូត្រស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ (M&E) ៣. វេទិការៀនសូត្រស្តីពីព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា (ICT) និងទី ៤. វេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ (Finance)។ វេទិការៀនសូត្រទាំងនេះពិតជាមានសារៈសំខាន់ណាស់ ក្នុងការកសាងសមត្ថភាពសមាជិកភាពរបស់ខ្លួន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបំពេញការងារ រួមទាំងលទ្ធផលក្នុងការផ្តល់សេវាកម្មរបស់អង្គការសមាជិក។

ដើម្បីធានានូវគុណភាពនៃវេទិការៀនសូត្រ អង្គការ **គសក** បានបង្កើតក្រុមការងារ (Working Group) ដើម្បីផ្តល់នូវធាតុចូល និងដំបូន្មានដល់អង្គការមិនមែនរដ្ឋាភិបាលនៅទូទាំងប្រទេសកម្ពុជា។ ហើយក្រុមការងារនេះ មានតួនាទីជាគណៈកម្មាធិការតម្រង់ទិសលើផ្នែកយុទ្ធសាស្រ្ត និងបច្ចេកទេស ដល់សហគមន៍អង្គការមិនមែនរដ្ឋាភិបាល ដើម្បីការអភិវឌ្ឍប្រកបសិទ្ធភាព និងប្រសិទ្ធពលនៅក្នុងប្រទេសកម្ពុជា។

ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាលនេះ អង្គការ **គសក** បានរៀបចំវេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៣៨ ក្រោមប្រធានបទ "**ការបើកប្រាក់អតីតភាពការងារ និងដំណោះស្រាយបណ្តឹងតវ៉ាបុគ្គលិក**" ។

## II. គោលបំណងនៃវេទិការៀនសូត្រ

- ដើម្បីត្រួតពិនិត្យឡើងវិញ លើលទ្ធផល និងផលជះនៃការរៀនសូត្រពីវេទិកាលើកមុន
- ដើម្បីបង្កើនការយល់ដឹងពី ប្រាក់អតីតភាពការងារ ( ការគណនា និងទូទាត់ប្រាក់អតីតភាពការងារ)
- ដើម្បីធ្វើការចែករំលែក និងពិភាក្សាពីការដោះស្រាយបណ្តឹងតវ៉ារបស់បុគ្គលិក ដើម្បីឲ្យអ្នកចូលរួមមានជម្រើសកាន់តែច្រើន ក្នុងការដោះស្រាយបណ្តឹងតវ៉ារបស់បុគ្គលិកប្រកបដោយប្រសិទ្ធភាព
- ដើម្បីចែករំលែក និងបង្កើនការយល់ដឹងពី សេចក្តីព្រាងអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- ដើម្បីពង្រឹង និង បង្កើនបណ្តាញទំនាក់ទំនងក្នុងចំណោមអ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិផ្នែកគ្រប់គ្រងធនធានមនុស្ស ក្នុងការរៀនសូត្រ និងចែករំលែកបទពិសោធន៍ស្តីពីបញ្ហានានាទាក់ទងនឹងការគ្រប់គ្រងធនធានមនុស្ស។

## III. លទ្ធផលរំពឹងទុក

- អ្នកចូលរួម នឹងទទួលបាននូវការយល់ដឹងកាន់តែប្រសើរ ក្នុងការអនុវត្តបើកប្រាក់អតីតភាពការងារ និងរបៀបគណនា
- អ្នកចូលរួម នឹងមានការយល់ដឹងកាន់តែច្បាស់លាស់ ទៅលើសេចក្តីព្រាងអនុក្រឹត្យ និងការរៀបចំផែនការអនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- អ្នកចូលរួម នឹងទទួលបានចំណេះដឹង និងបទពិសោធនជាក់ស្តែងបន្ថែម ពីរបៀបដោះស្រាយបណ្តឹងតវ៉ារបស់បុគ្គលិកប្រកបដោយប្រសិទ្ធភាព
- អ្នកចូលរួម អាចពង្រឹងបណ្តាញទំនាក់ទំនងក្នុងអាជីពជាអ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស

## IV. អ្នកចូលរួមគោលដៅ

វេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សនេះ នឹងមានអ្នកចូលរួមសរុបចំនួន ១០០នាក់ ដែលអញ្ជើញមកពី **អង្គការមិនមែនរដ្ឋាភិបាល** ដែលជា**អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស** ។

- **អង្គការសមាជិក** របស់ **គសក** អាចបញ្ជូនបុគ្គលិករបស់ខ្លួនចូលរួមចំនួន **២នាក់ /អង្គការ (ដោយឥតបង់ថ្លៃសេវា)**។ ក្នុងករណីអង្គការសមាជិកបញ្ជូនបុគ្គលិករបស់ខ្លួន**លើសពី ២នាក់/អង្គការ** អ្នកចូលរួមត្រូវបង់ថ្លៃសេវា ចំនួន **២៥ដុល្លារ/នាក់/វគ្គ**
- ដោយឡែក **អ្នកចូលរួមដែលមានមិនមែនជាអង្គការសមាជិករបស់ គសក** ក៏ត្រូវបានស្វាគមន៍ក្នុងវេទិការៀនសូត្រនេះផងដែរ ដោយត្រូវបង់ថ្លៃ **៥០ដុល្លារ/នាក់/វគ្គ**

***កំណត់សម្គាល់:*** ***តម្លៃដែលត្រូវបង់ក្នុងវេទិកានេះ គឺផ្អែកទៅលើគោលនយោបាយបង់ថ្លៃសេវាកម្មរបស់ អង្គការគសក ហើយទឹកប្រាក់ទាំងនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំវេទិការៀនសូត្រនេះ។***

## V. របៀបវារៈ:

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| 07:30-08:20 | ការចុះឈ្មោះអ្នកចូលរួម | • ក្រុមការងារ សគក |
| 08:20-08:30 | ការគោរពភ្លេងជាតិ | **លោក អ៊ិន សិទ្ធី**<br>អ្នកកាន់កម្មវិធីវេទិការៀនសូត្រ |
| | កិច្ចស្វាគមន៍ ណែនាំគោលបំណងវេទិការៀនសូត្រ និង ការជម្រាបជូនដំណឹង និងព័ត៌មានទូទៅ | |
| 08:30-08:50 | មតិស្វាគមន៍ និងប្រកាសបើកវេទិការៀនសូត្រ | **លោក សឿង សារឿន**<br>នាយកប្រតិបត្តិ អង្គការ គសក |
| 08:50-09:20 | **វគ្គទី១:** ការរំលឹកឡើងវិញពីលទ្ធផលនៃការពិភាក្សា កាលពីវេទិកាលើកមុន ស្ដីពី **ការគ្រប់គ្រងបំពេញការងារ** | **អ្នកស្រី សឿង សត្យា**<br>អ្នកឯកទេសគ្រប់គ្រងធនធានមនុស្ស<br>អង្គការ សគក |
| 09:20-09:40 | **ការសម្រាក** | អ្នកចូលរួមទាំងអស់ |
| 09:40-12:00 | **វគ្គទី២**: បទបង្ហាញពី ការប្រាក់អតីតភាពការងារ និង ច្បាប់ដែលពាក់ព័ន្ធ ( តាមសេចក្ដីណែនាំ លេខ៥៨)<br>សំណួរ & ចម្លើយ | **លោក ម៉ាញ ណារិទ្ធិ**<br>ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (MoLVT) |
| 12:00-01:30 | **សម្រាកអាហារថ្ងៃត្រង់រួមគ្នា** | |
| 01:30-02:00 | **វគ្គទី៣** : ការធ្វើបច្ចុប្បន្នភាព ទៅលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីរពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់គណនេយ្យនិងសវនកម្ម | **លោក យឿង សុធារ៉ា**<br>ប្រធានផ្នែក CAN<br>អង្គការ គសក |
| 02:00-02:30 | **វគ្គទី៤**: បទបង្ហាញស្ដីពី បណ្ដឹងតវ៉ាបុគ្គលិក និងដំណោះស្រាយ | **លោក ឈួន វុទ្ធី**<br>ប្រធានផ្នែកគ្រប់គ្រងធនធានមនុស្ស<br>អង្គការ PSI/C |
| 02:30-03:30 | **វគ្គទី៥**: កិច្ចពិភាក្សាវាគ្មិនស្ដីពីរបៀបដោះស្រាយបណ្ដឹងតវ៉ាបុគ្គលិកប្រកបដោយប្រសិទ្ធភាព<br>សំណួរ & ចម្លើយ | **វាគ្មិនៈ**<br>**លោក យន ប៊ុនថុង** អ្នកសម្របសម្រួល<br>**លោក ឈួន វុទ្ធី** (អង្គការ PSI/C)<br>**អ្នកស្រី ហេង រតនា** (អង្គការ WVI) |

| | | |
|---|---|---|
| 3:30-3:50 | **សម្រាក** | អ្នលចូលរួមទាំងអស់ |
| 03:50-04:10 | យោបល់ត្រឡប់ពីអ្នកចូលរួមស្តីពី វេទិការៀនសូត្រគ្រប់គ្រងធនធានមនុស្ស | • រាល់សមាសភាពអ្នកចូលរួមទាំងអស់ |
| 4:10-4:30 | - ការពិភាក្សាទៅលើ ប្រធានបទសម្រាប់វេទិកាគ្រប់គ្រង់ធនធានមនុស្សលើកក្រោយ<br>- ការវាយតម្លៃវេទិកាដោយអ្នកចូលរួម | ក្រុមការងារ គសក |
| 4:30-4:50 | **ការបូកសរុប និង បិទអង្គកម្មវិធី** | សមាជិកក្រុមការងារគ្រប់គ្រងធនធានមនុស្ស |

***កំណត់សម្គាល់:*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែ របៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។*